**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក**

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា ចូលរួមជាមួយឡាវ និងវៀតណាម ក្នុងការជំរុញភាពជាដៃគូ រវាងរដ្ឋ និងឯកជន ដើម្បីរួមចំណែកកសាងអនាគតចីរភាពក្នុងតំបន់អាស៊ាន

នៅព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញចូលរួមថ្លែងសុន្ទរកថាគន្លឹះនៅក្នុង**កម្មវិធីកិច្ចសន្ទនារវាងនាយករដ្ឋមន្ត្រីកម្ពុជា ឡាវ និង វៀតណាម** ជាមួយធុរជនអាស៊ាន ដែលបានប្រព្រឹត្តទៅក្នុងឱកាសកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន (ABIS) ក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៤ និង ៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ពីថ្ងៃទី៨ ដល់១១ ខែតុលា ឆ្នាំ២០២៤ នៅរដ្ឋធានីវៀងចន្ទន៍។

**សម្តេចធិបតី ហ៊ុន ម៉ាណែត** ព្រមទាំងនាយករដ្ឋមន្ត្រី**ឡាវ និងវៀតណាម** បានចែករំលែកទស្សនវិស័យស្តីពីការអភិវឌ្ឍប្រទេសរៀងៗខ្លួន ជាពិសេសការលើកទឹកចិត្តដល់ធុរជន និងវិនិយោគិន ការតភ្ជាប់សេដ្ឋកិច្ច ការធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងការអភិវឌ្ឍប្រកបដោយចីរភាព។ **សម្តេចធិបតី** ក៏ដូចជា**នាយករដ្ឋមន្ត្រីឡាវ និងវៀតណាម** បានគូសបញ្ជាក់ពីសារសំខាន់នៃការបន្តការប្រាស្រ័យទាក់ទងគ្នា និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសសេដ្ឋកិច្ច និងវិនិយោគ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ពាណិជ្ជកម្ម ទេសចរណ៍ ថាមពល និងឌីជីថល។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់សាជាថ្មីពីសារសំខាន់របស់អាស៊ាន ដែលវិនិយោគិនក្នុងតំបន់ និងអន្តរជាតិបានចាត់ទុកថាជាពន្លឺនៃក្តីសង្ឃឹម និងជាកម្លាំងចលករជំរុញកំណើនពិភពលោក ដោយសារតែសន្តិភាព និងស្ថិរភាពក្នុងតំបន់។ **សម្តេចធិបតី** ក៏បានបង្ហាញសុទិដ្ឋិនិយមចំពោះកំណើននៃទំនាក់ទំនងរវាងស្ថាប័នធុរកិច្ចពីបណ្តាសមាជិកអាស៊ានឯទៀតជាមួយប្រទេសកម្ពុជា ឡាវ និង វៀតណាម ដែលជាប្រទេសកំពុងមានការរីកលូតលាស់ជាបន្តបន្ទាប់ និងមានទីតាំងស្ថិតនៅកណ្តាលតំបន់អាស៊ាន។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥)
ទូរសារ : (៨៥៥) 23 216 1, 023 21 34
អ៊ីម៉ែល : m .gov.kh

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវិនិយោគិន និងធុរជនពីបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់ ទៅសិក្សា និងស្វែងយល់ពីបរិយាកាសអំណោយផល និងកាលានុវត្តភាពរបស់កម្ពុជា។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវអភិក្រមគាំទ្រធុរកិច្ចជានិច្ច ដោយផ្តល់ការគាំទ្រដល់វិស័យឯកជននៅគ្រប់ដំណាក់កាលនៃប្រតិបត្តិការអាជីវកម្មរបស់ពួកគេ៕

ថ្ងៃសៅរ៍ ១០កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៤